ឯកភាព អោយប្រធានក្រុមប្រឹក្សាភិបាល ធ្វើជាប្រធានអង្គប្រជុំ សូមមេត្តាលើកដៃឡើង។” ក្នុងករណី ដែលមានការឯកភាពពីសមាជិកភាគច្រើន ប្រធានក្រុមប្រឹក្សាភិបាលនោះនឹងក្លាយជាប្រធាននៃអង្គប្រជុំពេញសិទ្ធិ។

(៦) ការតែងតាំងលេខាធិការសម្រាប់អង្គប្រជុំ

ប្រធានអង្គប្រជុំ ត្រូវប្រកាសថា “នៅក្នុងមហាសន្និបាតត្រូវតែងតាំងលេខាធិការ១រូប ដើម្បីធ្វើកំណត់ហេតុពីសេចក្តីសម្រេចរបស់មហាសន្និបាត (មាត្រា៤២)។ ហេតុដូច្នេះ ខ្ញុំ សូមតែងតាំងលោក/លោកស្រី ....................ធ្វើជាលេខាធិការ។” ករណីពុំមានការជំទាស់ លោក/លោកស្រី រូបនោះនឹងត្រូវបានតែងតាំងជាលេខាធិការ។

(៧) របៀបវារៈគំរូ (មាត្រា៣៧)

ប្រធានអង្គប្រជុំ ត្រូវស្នើសុំសមាជិកក្រុមប្រឹក្សាភិបាល ឬសមាជិកគណៈកម្មាធិការត្រួតពិនិត្យមួយរូបធ្វើការបកស្រាយពន្យល់ពីរបៀបវារៈនិមួយៗ។ បន្ទាប់ពីបានធ្វើការពន្យល់រួចមក ប្រធានគួរជុំរុញឲ្យមានការសួរសំណួរ និងបញ្ចេញមតិយោបល់ពីសមាជិក។ ការអនុម័តសម្រេចរបស់សមាជិកលើរបៀបវារៈ នៃមហាសន្និបាតខាងក្រោម ត្រូវធ្វើឡើងដោយការបោះឆ្នោត តាមរយៈការលើកដៃគាំទ្រពីសមាជិកទាំងអស់៖

- ការអនុម័តលើ របាយការណ៍ជំនួញតារាងតុល្យការ និងរបាយការណ៍ចំណេញ/ខាត ក្នុងរយៈពេលពេញមួយឆ្នាំ។
- ការអនុម័តលើ ផែនការជំនួញ និងផែនការថវិកាក្នុងរយៈពេលពេញមួយឆ្នាំ ។
- ការអនុម័តលើ របាយការណ៍សវនកម្ម ។
- ការអនុម័តលើ របាយការណ៍ប្រចាំឆ្នាំ របស់គណៈកម្មាធិការត្រួតពិនិត្យ។
- ការអនុម័តលើ កំណត់ហេតុនៃកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ។
- ការអនុម័តលើ ចំនួនប្រាក់ចំណេញសុទ្ធសរុបប្រចាំឆ្នាំបន្ទាប់ពីបានដកនូវមូលនិធិបំរុង មូលនិធិបណ្តុះបណ្តាល មូលនិធិអប់រំមូលនិធិស្ម័គ្រចិត្ត សម្រាប់អភិវឌ្ឍន៍សហគមន៍កសិកម្ម និងការសងបំណុលពីឆ្នាំមុន ។
- ការអនុម័តលើ ការបែងចែកប្រាក់ភាគលាភដល់សមាជិកសហគមន៍កសិកម្ម ។
- ការអនុម័តលើ ការអនុវត្តមុខជំនួញថ្មី ។
- ការអនុម័តផ្សេងៗ ដែលបានកំណត់តាំងពីការប្រជុំក្រុមប្រឹក្សាភិបាលខាងលើ។

### ៣.២ ការបោះឆ្នោត

សមាជិកម្នាក់ៗ មានសំឡេងតែមួយគត់ នៅក្នុងអង្គប្រជុំមហាសន្និបាត។ សេចក្តីសម្រេចនានា ដែលទាក់ទងទៅនឹងលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ការបំបែកសហគមន៍កសិកម្ម ការបញ្ចូលសហគមន៍កសិកម្ម ឬការបណ្តេញចេញសមាជិកណាម្នាក់ ត្រូវមានការយល់ព្រមពីសមាជិកវត្តមាន ក្នុងអង្គប្រជុំចំនួន២ភាគ៣ នៃសមាជិកវត្តមានសរុប ។ (មាត្រា៤៣)

## ជំហានទី៤: កិច្ចការដែលត្រូវធ្វើបន្ទាប់ពីមហាសន្និបាតប្រចាំឆ្នាំ

### ១.ការរៀបចំកំណត់ហេតុ

លេខាធិការ ត្រូវរៀបចំនូវកំណត់ហេតុនៃមហាសន្និបាត ហើយប្រធានអង្គប្រជុំ និងលេខាធិការ ត្រូវចុះហត្ថលេខាលើកំណត់ហេតុនោះ។ (មាត្រា៤២)

### ២ ការរក្សាទុកឯកសារនានា

សហគមន៍កសិកម្ម ត្រូវរក្សាទុកនូវឯកសារនានាដែលបានអនុម័តដោយមហាសន្និបាត និងកំណត់ហេតុ នៅទីស្នាក់ការសហគមន៍កសិកម្ម ។

# គោលការណ៍ណែនាំស្តីពីការរៀបចំមហាសន្និបាតប្រចាំឆ្នាំរបស់សហគមន៍កសិកម្ម




## រៀបចំដោយ:

គម្រោងបង្កើតសហគមន៍កសិកម្មគំរូដែលតម្រង់ទិសដៅទៅលើការធ្វើជំនួញ (BPAC)

អាសយដ្ឋានលេខៈ៥៤ បេ/៤៩អេហ្វ ផ្លូវ ៣៩៥-៦៥៦ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ទូរស័ព្ទលេខ (០២៣) ៨៨៣ ៤២៧ ទូរសារលេខ
Address#54B/49F.St395-656,Sangkat Toeuk Laak 3 Khan Tuol Kok ,Phnom penh ,Cambodia,phone: (023) 883 427, Fax : 023) 883 427

មហាសន្និបាត ជាអង្គការជាន់ខ្ពស់បំផុតរបស់សហគមន៍កសិកម្ម ដែលមានភារកិច្ចធ្វើការអនុម័ត និងធ្វើសេចក្តីសម្រេចចិត្តទាំងឡាយក្នុងដំណើរការបង្កើត និងការប្រព្រឹត្រទៅរបស់សហគមន៍កសិកម្ម ដែលរួមមានមហាសន្និបាតកំណើតដំបូង មហាសន្និបាតប្រចាំឆ្នាំ មហាសន្និបាតតំណាង និង មហាសន្និបាតវិសាមញ្ញ។ (មាត្រា៣៧)

មហាសន្និបាតប្រចាំឆ្នាំរបស់សហគមន៍កសិកម្ម ត្រូវរៀបចំឡើងមួយឆ្នាំម្តង និងមានភារកិច្ចសំខាន់ នៅក្នុងការអនុម័តនូវរបៀបវារៈ។ (មាត្រា៣៩)

ប្រសិនបើសហគមន៍កសិកម្ម មិនបានរៀបចំមហាសន្និបាតប្រចាំឆ្នាំទេសហគមន៍កសិកម្មនោះ នឹងត្រូវព្រមានជាលាយល័ក្ខអក្សរស្របតាមច្បាប់ស្តីពីសហគមន៍កសិកម្ម ។ (មាត្រា១០៨)

ប្រសិនបើសហគមន៍កសិកម្ម មិនបានរៀបចំមហាសន្និបាតប្រចាំឆ្នាំរយៈពេលពីរឆ្នាំជាប់ៗគ្នា ដោយមិនមាននូវមូលហេតុសមស្របទេ សហគមន៍កសិកម្មនោះ នឹងត្រូវបានដកហូតវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជី។ (មាត្រា១០៩)

ខិតប័ណ្ណនេះរៀបចំឡើង ក្នុងគោលបំណងណែនាំស្តីពីនិតិវិធីនៃការរៀបចំមហាសន្និបាតប្រចាំឆ្នាំ ដែលយោងតាមច្បាប់ស្តីពីសហគមន៍កសិកម្ម ។

## ជំហានទី១: ការកោះប្រជុំក្រុមប្រឹក្សាភិបាល

ការប្រជុំក្រុមប្រឹក្សាភិបាល ត្រូវធ្វើឡើងដើម្បីកំណត់នូវកាលបរិច្ឆេទឱ្យបានត្រឹមត្រូវ (ថ្ងៃ ខែ ឆ្នាំ) ពេលវេលា ទីកន្លែង និងតួនាទី ដូចជា:

១. រៀបចំមហាសន្និបាត ប្រចាំឆ្នាំរបស់សហគមន៍កសិកម្ម

២. ដាក់ជូនមហាសន្និបាត នូវរបាយកាណ៍ប្រចាំឆ្នាំ រួមមានតារាងតុល្យការដែលបានឯកភាពដោយគណៈកម្មាធិការ ត្រួតពិនិត្យ ។

៣. ដាក់ជូនមហាសន្និបាត នូវផែនការសកម្មភាព និងផែនការហិរញ្ញវត្ថុសម្រាប់ឆ្នាំក្រោយ (មាត្រា៤៧)។

## ជំហានទី២: សេចក្តីជូនដំណឹងស្តីពីការរៀបចំមហាសន្និបាត

ក្រុមប្រឹក្សាភិបាល ជាអ្នកផ្សព្វផ្សាយព័ត៌មាន ពាក់ព័ន្ធនឹងមហាសន្និបាតប្រចាំឆ្នាំរបស់សហគមន៍កសិកម្ម។ សេចក្តីជូនដំណឹងលំអិតអំពីទីកន្លែង កាលបរិច្ឆេទ និងរបៀបវារៈរបស់មហាសន្និបាត នឹងត្រូវផ្សព្វផ្សាយ និងបិទប្រកាសនៅខាងមុខការិយាល័យ យ៉ាងហោចណាស់ ១០ ថ្ងៃមុនមហាសន្និបាត ។

ឧទាហរណ៍ នៅក្នុងករណីដែលមហាសន្និបាត ត្រូវធ្វើឡើងនៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៣ សេចក្តីជូនដំណឹង គួរតែបិទប្រកាសនៅថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៣ ឬ មុនថ្ងៃទី៥។

ខាងក្រោមនេះ ជាបែបបទគំរូមួយនៃសេចក្តីជូនដំណឹង៖

១. កាលបរិច្ឆេទនៃការជូនដំណឹង៖ ថ្ងៃទី.....ខែ......ឆ្នាំ......
២. ប្រធានបទ៖ ការកោះប្រជុំមហាសន្និបាតជាលើកទី........
មហាសន្និបាតលើកទី......នឹងត្រូវធ្វើឡើងដូចក្នុងសេចក្តីជូនដំណឹងខាងក្រោម ហើយសមាជិកទាំងអស់ត្រូវបានអញ្ជើញអោយចូលរួម មហាសន្និបាត ។
៣. កាលបរិច្ឆេទ៖ ថ្ងៃទី............ខែ..........ឆ្នាំ...........
៤. ទីកន្លែង៖ .............................................................
៥. របៀបវារៈ៖ ...........................................................

## ជំហានទី៣: ដំណើរការបើកមហាសន្និបាតប្រចាំឆ្នាំ

### ៣.១. ដំណើរការបើកមហាសន្និបាតប្រចាំឆ្នាំ

(១) ការបើកមហាសន្និបាត

ក្រុមប្រឹក្សាភិបាលមួយរូប ក្រៅពីប្រធានឬប្រធានប្រតិបត្តិ គឺជាអ្នក ប្រកាសបើកមហាសន្និបាត។

(២) គោរពភ្លេងជាតិនៃព្រះរាជាណាចក្រកម្ពុជា

(៣) សន្ទរកថាបើកមហាសន្និបាត

(៤) ការបញ្ជាក់ពីចំនួនអ្នកចូលរួម

ក្រុមប្រឹក្សាភិបាលមួយរូប ក្រៅពីប្រធានឬប្រធានប្រតិបត្តិ ត្រូវរាប់ចំនួនអ្នកចូលរួម ហើយប្រកាសថា “សមាជិកសហគមន៍កសិកម្មសរុបមានចំនួន......នាក់ ហើយអ្នកដែលចូលរួមមហា សន្និបាតសរុបមានចំនួន.........នាក់។ ដូច្នេះមហាសន្និបាតប្រចាំឆ្នាំ របស់សហគមន៍កសិកម្មអាចប្រព្រឹត្តទៅជាធម្មតាបាន (ឬមិនអាចប្រព្រឹត្តទៅបាន)។”

មហាសន្និបាតប្រចាំឆ្នាំ អាចប្រព្រឹត្តទៅបានលុះត្រាតែ មានចំនួនសមាជិកសហគមន៍កសិកម្មចូលរួមយ៉ាងតិច ស្មើនឹងពីរភាគបី (២/៣) នៃចំនួនសមាជិកសហគមន៍កសិកម្ម សរុប។ (មាត្រា៤២)

ឧទាហរណ៍ ក្នុងករណីដែលសហគមន៍កសិកម្ម មានសមាជិកសរុបចំនួន១០០នាក់ នោះសមាជិកចូលរួមមហាសន្និបាត ត្រូវមានចំនួនយ៉ាងតិចស្មើនឹង៦៧នាក់។ ចំពោះអ្នកតំណាងឬសមាជិកគ្រួសារមិនអាចរាប់បញ្ចូលជាសមាជិកចូលរួមបានទេ ។

ក្នុងករណីដែលលក្ខណ្ឌខាងលើ ពុំអាចបំពេញបានទេ ការកោះប្រជុំមហាសន្និបាតជាលើកទី២ លើរបៀបវារៈដដែល នឹងត្រូវធ្វើឡើងក្នុងរយៈពេល១០ថ្ងៃបន្ទាប់ពីថ្ងៃកំណត់នៃមហា សន្និបាតលើកទី១។ មហាសន្និបាតលើកទី២នោះ ពុំកំណត់ចំនួនសមាជិកសហគមន៍កសិកម្មចូលរួមឡើយ។ (មាត្រា៤២)

(៥) ការបោះឆ្នោតជ្រើសរើសប្រធានអង្គប្រជុំ

ក្រុមប្រឹក្សាភិបាលមួយរូប ក្រៅពីប្រធានឬប្រធានប្រតិបត្តិ នឹងធ្វើសេចក្តីប្រកាសថា “មហាសន្និបាត ត្រូវដឹកនាំដោយប្រធានក្រុមប្រឹក្សាភិបាល ឬប្រធានអង្គប្រជុំ ដែលត្រូវបានជ្រើសរើសដោយការបោះឆ្នោតពីក្នុងចំណោមសមាជិកចូលរួមទាំងអស់។ ហេតុដូច្នេះ សមាជិក ត្រូវធ្វើការសម្រេចចិត្ត ជ្រើសរើសប្រធានអង្គប្រជុំមួយរូប។”

ក្នុងករណីដែលមិនមានសមាជិករូបណា មានយោបល់នោះក្រុមប្រឹក្សាភិបាលមួយរូប នឹងប្រកាសថា “ប្រធានក្រុមប្រឹក្សាភិបាល នឹងក្លាយជាប្រធានអង្គប្រជុំ” ហើយប្រធានក្រុមប្រឹក្សាភិបាលនោះ នឹងក្លាយជាប្រធានអង្គប្រជុំពេញសិទ្ធិ។

ក្នុងករណីដែលមានសមាជិក ធ្វើការណែនាំសមាជិក ដទៃទៀតក្នុងការឈរឈ្មោះធ្វើជាប្រធានអង្គប្រជុំ នោះក្រុមប្រឹក្សាភិបាលមួយរូបនឹងប្រកាសថា “បើសិនជាសមាជិទាំងអស់ ឯកភាពអោយសមាជិករូបនេះធ្វើជាប្រធាននៃអង្គប្រជុំ សូមមេត្តាលើកដៃឡើង។” ក្នុងករណីដែលសមាជិកភាគច្រើន មានការឯកភាព សមាជិករូបនោះ នឹងក្លាយជាប្រធាន អង្គប្រជុំពេញសិទ្ធិ។

ក្នុងករណីដែលមានសមាជិកភាគច្រើន មិនឯកភាព នោះក្រុមប្រឹក្សាភិបាលមួយរូប នឹងប្រកាសថា “បើសិនជាសមាជិកទាំងអស់